**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៥៩ . អនក្រ . បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតអគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១:-** ត្រូវបានបង្កើតអគ្គនាយកដ្ឋាននយោបាយនិងកិច្ចការបរទេស ចំណុះក្រសួងការពារជាតិ បំពេញបន្ថែមក្នុងរចនាសម្ព័ន្ធនៃអនុក្រឹត្រលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ ។

## ជំពូកទី ២
## តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា ២:-** អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស មានតួនាទី និងភារៈកិច្ចដូចតទៅ:

- សិក្សាស្រាវជ្រាវនិងកសាងផែនការអំពីនយោបាយយុទ្ធសាស្ត្រនៃវិស័យការពារជាតិ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល
- អនុវត្តពង្រឹង និងពង្រីក កិច្ចសហប្រតិបត្តិការយោធាជាមួយបណ្ដាប្រទេស
- សម្របសម្រួលការងារការទូត និងលិខិតស្នាមឆ្លងដែន សម្រាប់កងយោធពលខេមរភូមិន្ទ
- លើកយោបល់ជូនថ្នាក់ដឹកនាំ ក្រសួងការពារជាតិ ក្នុងកិច្ចការការពារសន្តិសុខការពារជាតិ និងកិច្ចការបរទេស ដែលទាក់ទងនឹងវិស័យការពារជាតិ
- ធ្វើកិច្ចសហប្រតិបត្តិការផ្នែកសន្តិសុខលើឆាកអន្តរជាតិនៅក្នុងក្របខណ្ឌទ្វេភាគី ពហុភាគី និងយន្តការសន្តិសុខក្នុងតំបន់ និងអន្តរជាតិ
- រៀបចំ និងគ្រប់គ្រងសេនាទុព័ន្ធយោធាប្រចាំនៅបណ្ដាប្រទេស
- សម្របសម្រួលការងាររបស់អ្នកបំពេញបេសកកម្ម និងកម្មសិក្សាការី នៅក្រៅប្រទេស
- ធ្វើការងារដែលពាក់ព័ន្ធនឹងកិច្ចការអាស៊ាន លើវិស័យការពារជាតិ
- ធ្វើការសម្របសម្រួល ជាមួយបណ្ដាក្រសួង ស្ថាប័នពាក់ព័ន្ធ ជាពិសេសយន្តការសម្របសម្រួល របស់រាជរដ្ឋាភិបាល សម្រាប់ ការបំពេញ បេសកកម្ម ប្រតិបត្តិការសន្តិភាព របស់កងយោធពលខេមរភូមិន្ទ នៅក្នុងក្របខណ្ឌអង្គការសហ - ប្រជាជាតិ
- ធ្វើការទំនាក់ទំនង និងសហការជាមួយ ក្រសួងស្ថាប័នអង្គភាព និងអាជ្ញាធរ ដែលពាក់ព័ន្ធនឹងយុទ្ធសាស្ត្រការពារជាតិ ដើម្បីកសាង នយោបាយសន្តិសុខ និងការពារជាតិ ប្រកបដោយប្រសិទ្ធភាព និងតម្លាភាព
- ធ្វើការអភិវឌ្ឍឯកសារកសាងនយោបាយការពារជាតិ រួមមានសៀវភៅ ស ការពារជាតិ និងឯកសារពាក់ព័ន្ធ
- ធ្វើប្រតិកម្ម ឬបំភ្លឺ ក្នុងនាមក្រសួងការពារជាតិ ចំពោះព័ត៌មានអវិជ្ជមានទាំងឡាយ ទាក់ទងនឹងវិស័យការពារជាតិ
- ស្វែងរកជំនួយនិងកិច្ចសហប្រតិបត្តិការពីសំណាក់អន្តរជាតិ ព្រមទាំងសម្របសម្រួលការងារទាំងឡាយ សំរាប់គាំទ្រដល់ដំណើរការកែទម្រង់កងយោធពលខេមរភូមិន្ទ និងការកសាងសមត្ថភាពផ្នែកប្រតិបត្តិការសន្តិភាព
- គ្រប់គ្រង និងអភិវឌ្ឍសមត្ថភាពផ្នែកព័ត៌មានវិទ្យា
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលរដ្ឋមន្ត្រីក្រសួងការពារជាតិប្រគល់ឱ្យ ។

**មាត្រា ៣:-** អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស មានរចនាសម្ព័ន្ធដូចតទៅ:

- នាយកដ្ឋាននយោបាយផែនការ "នាយកដ្ឋាននេះត្រូវបានផ្ទេរមកពីនាយកដ្ឋាននយោបាយ ផែនការ ចំណុះក្រសួងការពារជាតិ ដែលមានស្រាប់"
- នាយកដ្ឋានទាក់ទងអន្តរជាតិ "នាយកដ្ឋាននេះត្រូវបានផ្ទេរមកពីនាយកដ្ឋានអន្តរជាតិ នៃអគ្គនាយកដ្ឋានយោធសេវា ចំណុះក្រសួងការពារជាតិ ដែលមានស្រាប់"
- នាយកដ្ឋានប្រតិបត្តិការសន្តិភាព

អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស ដឹកនាំដោយអគ្គនាយកមួយរូប និងអគ្គនាយករងមួយចំនួនជាជំនួយតាមការចាំបាច់ ។

-អង្គការលេខរបស់អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ

**មាត្រា ៤:-** នាយកដ្ឋានប្រតិបត្តិការសន្តិភាពមានភារកិច្ចដូចតទៅ:

- ធ្វើការសម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធនានា ជាពិសេសយន្តការសម្របសម្រួលរបស់រាជរដ្ឋាភិបាលសម្រាប់ការបំពេញបេសកកម្មប្រតិបត្តិការសន្តិភាពរបស់កងយោធពលខេមរភូមិន្ទ នៅក្នុងក្របខណ្ឌអង្គការសហប្រជាជាតិ
- ស្វែងរកជំនួយ និងកិច្ចសហប្រតិបត្តិការពីសំណាក់អន្តរជាតិ សំរាប់កិច្ចការប្រតិបត្តិការសន្តិភាព
- កសាងផែនការ ដើម្បីកសាងកំលាំង និងសមត្ថភាពរបស់កងយោធពលខេមរភូមិន្ទ នៅក្នុងផ្នែកប្រតិបត្តិការសន្តិភាព
- សម្របសម្រួលបេសកកម្មរក្សាសន្តិភាពរបស់កងយោធពលខេមរភូមិន្ទនៅបរទេស
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលអគ្គនាយកប្រគល់ឱ្យ ។

នាយកដ្ឋានប្រតិបត្តិការសន្តិភាព ដឹកនាំដោយនាយកមួយរូប និងនាយករងមួយចំនួនជាជំនួយការតាមការចាំបាច់ ។

**មាត្រា ៥:-** តួនាទីភារកិច្ច និងក្របខណ្ឌរបស់ការិយាល័យ ដែលចំណុះផ្ទាល់អគ្គនាយកដ្ឋាន នយោបាយ និងកិច្ចការបរទេស និងនាយកដ្ឋានចំណុះ គឺអាស្រ័យដោយរដ្ឋមន្ត្រីក្រសួងការពារជាតិកំណត់ ។

## ជំពូកទី ៣

## អវសានប្បញ្ញត្តិ

**មាត្រា ៦:-** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៧:-** រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គរមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន ពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ឆ្នាំ២០០៨

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

បានយកសេចក្តីជំរាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រីសូមចុះហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ បាញ់**

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៥៥៦/អនក្រ.បក ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៨

អង្គការលេខអគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស នៃក្រសួងការពារជាតិ

